# ការយល់ដឹងអំពីកម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

នាងខ្ញុំឈ្មោះ យួម លីនណាជានិស្សិតឆ្នាំទី៣ មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកជីវវិទ្យា។ នាងខ្ញុំមានស្រុកកំណើត នៅភូមិនិគមន៍ ឃុំស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់។

បន្ទាប់ពីបានស្តាប់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលកម្ពុជា ដែលបានផ្សាយអំពីអំពើប្រល័យពូជសាសន៍នៅក្នុងរបបខ្មែរក្រហមរួចមក នាងខ្ញុំ មានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះកម្មវិធីនេះ។ ថ្វីត្បិត ខ្ញុំជានិស្សិតដែលសិក្សាផ្នែកជីវវិទ្យា ប៉ុន្តែ នាងខ្ញុំពិតជាមានសេចក្តីរំភើបយ៉ាងខ្លាំង ដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយជាសាធារណៈ នូវអំពើប្រល័យពូជសាសន៍ដ៏ឃោរឃៅមួយនេះ។ ក្រោយពីបានស្តាប់កម្មវិធីវិទ្យុសហគមន៍នេះរួចមក ខ្ញុំបានទទួលចំណេះដឹងយ៉ាងច្រើនអំពីបញ្ហានៃអំពើប្រល័យពូជសាសន៍ នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៥ ដល់១៩៧៩។ ជាមួយគ្នានេះផងដែរ នៅក្នុងរបបខ្មែរក្រហមបានធ្វើទារុណកម្ម ធ្វើទុក្ខបុកម្នេញ ដោយបង្អត់អាហារប្រជាពលរដ្ឋខ្មែរគ្មានឯង និងបង្ខំអោយប្រជាជនធ្វើការងារគ្មានពេលឈប់សំរាក។ ហេតុការណ៍ទាំងអស់នេះជាបញ្ហាចំបងដែលបង្កអោយប្រជាជនមានភាពអត់ឃ្លាននៅក្នុងរបបនោះ។ ការកើតឡើងនូវភាពអត់ឃ្លាននេះ នៅមិនទាន់បានដោះស្រាយនៅឡើយទេនៅបណ្តាប្រទេសមួយចំនួន។ ម្យ៉ាងវិញទៀត មិនថាតែប្រទេសកម្ពុជាទេដែលមានភាពអត់ឃ្លាន សូម្បីតែប្រទេសកូរ៉េខាងជើង និងប្រទេសអេចូពីក៏ជួបប្រទះនូវភាពអត់ឃ្លាននេះដែរ។ ដូច្នេះហើយ ខ្ញុំសង្កេតឃើញថាភាពអត់ឃ្លាន គឺកើតមានឡើងស្ទើរតែគ្រប់ប្រទេសទាំងអស់ នៅលើពិភពលោក។

ជារួមមក ក្នុងនាមខ្ញុំជាកូនខ្មែរ ខ្ញុំពិតជាមានភាពរន្ធត់ និង សោកស្តាយយ៉ាងខ្លាំងដែលប្រទេសកម្ពុជាជួបប្រទះនូវរបបដ៏សាហាវព្រៃផ្សៃនេះ។ ដូចនេះ ខ្ញុំនឹងខិតខំធ្វើការពន្យល់ និងផ្សព្វផ្សាយដល់ក្មេងជំនាន់ក្រោយអោយយល់ដឹងកាន់តែច្បាស់ពីរបបនេះ និងអោយពួកគេគិតពិចារណា ហើយសិក្សាអំពីរឿងរ៉ាវទាំងអស់នេះទុកជាបទពិសោធន៍ទៅថ្ងៃក្រោយ។ ជាពិសេស ធ្វើយ៉ាងណាកុំអោយរបបនេះកើតមានឡើងសារជាថ្មីនៅក្នុងប្រទេសកម្ពុជាយើងម្តងទៀត។ ជាចុងបញ្ចប់ ខ្ញុំសំនូមពរអោយកម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅតែបន្តធ្វើការចាក់ផ្សាយអោយបានច្រើនជាងមុនទៅទៀត ដើម្បីអោយសិស្សនិស្សិតបានយល់ដឹងកាន់តែច្បាស់បន្ថែមទៀត។

# My Personal Reflection on DC-Cam Community Program[1]

My name is Youm Linna. I am a third-year student majoring in biology at the Royal University of Phnom Penh. I was born in Nikom village, Svay Doun Keo commune, Ba Kan district, Pursat province.

I am very interested in DC-Cam's community radio program since I can gain a lot of knowledge regarding Khmer Rouge history. Through the episodes of the program I learnt that the Khmer Rouge tortured, starved and put its own people into hard labor. I also learnt that famine did not only happen in Cambodia, but also in some other countries like in Ethiopia and North Korea; such problems are not solved yet. Therefore, we can see that famine happens in many places in the world.

As a Cambodian citizen, I am really frightened and feel regret for the Cambodian experience under the harsh regime. Therefore, I will spread my knowledge about the history of Khmer Rouge to the younger generation and work together to prevent genocide from happening again. Last but not least, I would like to ask DC-Cam to increase the duration of the program, so that students can have more opportunity to learn about the regime.

---

[1] Translated by Lorn Dalin; edited by Tan Sock Keng